ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បាក់ព្រា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០០៨- ២០១០)

ឈ្មោះសហគមន៍នេសាទ : បាក់ព្រា
ភូមិ : បាក់ព្រា
ឃុំ : ព្រៃចាស់
ស្រុក : ឯកភ្នំ
ខេត្ត : បាត់ដំបង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទបាក់ព្រា ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី១២ ខែតុលា ឆ្នាំ ២០០៣ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។

សហគមន៍នេសាទ បាក់ព្រា មានទីតាំងស្ថិតនៅក្នុង ភូមិបាក់ព្រា ឃុំព្រៃចាស់ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានសមាជិកសរុបចំនួន ២១៤នាក់ ស្រី ចំនួន ៧៨នាក់ និងមានគណៈកម្មការចំនួន ០៩នាក់ ស្រីចំនួន ០១នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ៩៥គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

-កសាងសមាជិកភាពសហគមន៍នេសាទ

-ល្បាត ក្នុងកន្លែងនេសាទសហគមន៍

-ការប្រជុំផ្សព្វផ្សាយ អំពីសារៈប្រយោជន៍នៃធនធានធម្មជាតិ និងសហគមន៍នេសាទ

-ពិភាក្សារៀបចំ ផែនទីកន្លែងនេសាទសហគមន៍

-ប្រជុំប្រចាំខែ

-រៀបចំមហាសន្និបាតសហគមន៍នេសាទ អនុម័តឯកសារសំខាន់ៗ ដូចជាលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងបញ្ជីឈ្មោះសមាជិក។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ចំនួន ១ ៤៨៥នាក់ ( ប្រុស ចំនួន ៧១៥នាក់ ស្រី ចំនួន ៧៧០នាក់) ក្នុងនោះមានជនជាតិខ្មែរ ចំនួន ១ ៤៨៥នាក់។

-ចំនួនស្ត្រី-មេម៉ាយក្នុងសហគមន៍នេសាទមានចំនួន២៥នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទសរុបមានចំនួន ០៤នាក់ ក្នុងនោះស្រីចំនួន ០២នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទសរុបមានចំនួន ៣០នាក់ ក្នុងនោះស្រីចំនួន ២០នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទសរុបមានចំនួន ០១នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទសរុបមានចំនួន ០៤នាក់ ក្នុងនោះស្រីចំនួន ០៣នាក់

-ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

-ក្នុងចំណោមសមាជិកគ្រួសារ នៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរមាន ចំនួន ១ ១៧៤នាក់ ក្នុងនោះស្រីចំនួន ៥៩២នាក់ ករិតថ្នាក់បឋមសិក្សាចំនួន ២៨១នាក់ ក្នុងនោះស្រីចំនួន ១៧២នាក់ ករិតមធ្យមសិក្សា ចំនួន ៣០នាក់ ក្នុងនោះស្រី ចំនួន ០៦នាក់។

**៩-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ រួមមាន:

-នេសាទចំនួន ៣៦២ គ្រួសារ

-ចិញ្ចឹមត្រីចំនួន ៥០ គ្រួសារ ចំនួន ៥០ បែរ

-ចិញ្ចឹមក្រពើចំនួន ៦ គ្រួសារ ចំនួន ៦ បែរ

-ចិញ្ចឹមអន្ទង់ចំនួន ៦០ គ្រួសារ ចំនួន ៦០ បែរ

-កាប់អុសចំនួន ៥០ គ្រួសារ ចំនួន ១០០ ស្ទែរ

-លក់ដូរចំនួន ៣០ គ្រួសារ

-ចិញ្ចឹមជ្រូកចំនួន ២០ គ្រួសារ ចំនួន ៦០ ក្បាល

-ចិញ្ចឹមមាន់-ទាចំនួន ១០០ គ្រួសារ ៣០០ ក្បាល

-គ្រូបង្រៀនចំនួន ៣ គ្រួសារ

-ពេទ្យចំនួន ៣ គ្រួសារ

-កម្មករ ទៅថៃចំនួន ២ គ្រួសារ

-ជាងឈើចំនួន ៥ គ្រួសារ

-ជាងដេរ ចំនួន ៤ គ្រួសារ

-ឈ្មួញទិញត្រីចំនួន ៨ គ្រួសារ

-ប៉ូលីសចំនួន ៣ គ្រួសារ

-ជលផលចំនួន ១ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍នេសាទ បាក់ព្រា ជាកន្លែងដែលត្រូវបានកាត់ចេញពីនាទីឡូត៍នេសាទលេខ៩ ១០ និងលេខ១១។

កន្លែងនេសាទសហគមន៍នេសាទបាក់ព្រា មានទំហំ ៧០៧ហិកតា និងមានកំណត់និយាមកាដូចមានរំចង នៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

-ខាងជើងទល់និង ឡូត៍០៩-១០និង១១

-ខាងត្បូងទល់និង ស្ទឹងសង្កែ

-ខាងកើតទល់និង ស្ទឹងសង្កែ

-ខាងលិចទល់និង សហគមន៍នេសាទព្រែកត្រប់

## ៩. ផែននេសាទ

កន្លែងនេសាទសហគមន៍ បាក់ព្រា មានបឹងចំនួន០៧ អូរចំនួន ១១ ក្រឡុកចំនួន ០៥ ទំនាបចំនួន ០៦ និងស្រះចំនួន ០១ ដែលក្រឡុក អូរ ស្រះ ទំនាប រីងទឹកនៅរដូវប្រាំង។ ព័ត៌មានលំអិតលើទីតាំងកន្លែងនេសាទនីមួយៗ មានដូចខាងក្រោម៖

| | | |
|---|---|---|
| -បឹង តាអូរ | ១៥ x ១០០x 0.៥ | ខែ០១ ដល់ខែ០៦ |
| -បឹង កន្លះនាល | ២០ x ២០x 0.៤ | ខែ០១ ដល់ខែ០២ |
| -បឹង អាឆែបមាត់ | ២០ x ២០ x 0.៤ | ខែ០១ ដល់ខែ០២ |
| -បឹង សុំភ្លើង | ២០ x ២០ x 0.៤ | ខែ០១ ដល់ខែ០២ |
| -បឹង តាតែន | ២៥ x ២៥x 0.៤ | ខែ០១ ដល់ខែ០២ |
| -បឹង កូនភេ | ២០ x ២០ x 0.៤ | ខែ០១ ដល់ខែ០២ |
| -បឹង ត្រស់ | ៣០ x ៤០ x 0.៧ | ខែ០១ ដល់ខែ០៥ |
| -ក្រឡុកបឹង តាអូរ | ១០ x ១០ x 0.៣ | ខែ០១ ដល់ខែ០៦ |
| -ក្រឡុកបឹង ស្មោរ | ១៥ x ១៥ x 0.៤ | ខែ០១ ដល់ខែ០២ |
| -ក្រឡុកបឹង រីម | ៥ x ៥ x 0.៣ | ខែ០១ ដល់ខែ០២ |
| -ក្រឡុកបឹង ហឿង | ១០ x ១០ x 0.៣ | ខែ០១ ដល់ខែ០២ |
| -ក្រឡុកបឹង យាយបា | ១០ x ១០ x 0.៣ | ខែ០១ ដល់ខែ០២ |
| -អូរ តាសំ | ២ x ៤០x ១ | ខែ០១ |
| -អូរតាហ៊ីង | ២ x ៤០x ១ | ខែ០១ |
| -អូរចំការស្វ | ១x ២០x 0.៧ | ខែ០១ |
| -អូរតាឡុក | ១x ២០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរអាគី | ១x ១០០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរ តាតែន | ១x ៥០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរតាអូរ | ១x ៥០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរតាធី | ១x ៥០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរយាយបា | ១x ៧០x 0.៧ | ខែ០១ ដល់ខែ០២ |
| -អូរតាណយ | ១x ៤០x 0.៧ | ខែ០១ |
| -ទំនាបតាឡុក | ៤០x ៤០x 0.៥ | ខែ០១ |
| -ទំនាបតាតែន | ៨០x ៨០x 0.៥ | ខែ០១ |
| -ទំនាបតំណាក់បារាំង | ២០x ៨០x 0.៤ | ខែ០១ |
| -ទំនាបតាអូរ | ៨០x ៨០x 0.៤ | ខែ០១ |
| -ទំនាបអូរយាយបា | ៤០x ៤០x 0.៤ | ខែ០១ |

-ទំនាបទល់មុខដើមទឹកដោះគោ ៣០x ៥០x ០.៤ ខែ០១

-ស្រះវត្តបាក់ព្រា ២០x ៨០x ១ ខែ០១

-វាលស្រែគ្របដណ្តប់ដោយស្មៅ ទំហំ០,២០ហិតា

-ព្រៃគម្ពោច និងរនាមលិចទឹក ទំហំ ៦៧០,២៦ ហិកតា

-ស្មៅលិចទឹក ទំហំ១៤,៦៣ ហិចតា

-វាលស្រែ ( ស្រូវវស្សា ស្រូវប្រាំង ស្រូវប្រដេញទឹក) ទំហំ៦,៨៨ហិចតា

-ផ្ទៃទឹក ( បឹង ទន្លេ ស្ទឹង ព្រែក និងអូរ ) ទំហំ៧,០០ហិចតា

-ដីភូមិ ចំការក្នុងភូមិ ទំហំ០,៩០ហិតា

-ដីចំការដំណាំកសិកផល ( ពោត សណ្តែក ឪឡឹក) ទំហំ៥,៨៨ ហិតា

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

-ស្រះវត្តបាក់ព្រា មានបណ្តោយ ១០០ម ទទឹង ២០ម និងជំរៅ ១ម

-កន្លែងអភិរក្សព្រៃលិចទឹក ចំណុចទំនាបតាទែន មានបណ្តោយ ១.០០០មទទឹង ១.០០០ម ។

## ឃ. ធនធានជលផល

ធនធានជលផល ក្នុងកន្លែងនេសាទសហគមន៍បាក់ព្រា មានត្រី ចំនួន ៥២ប្រភេទ វារីសត្វ ចំនួន ២១ប្រភេទ ព្រៃលិចទឹក ចំនួន ៣៥ប្រភេទ និងវារីរុក្ខជាតិ ចំនួន ២០ប្រភេទ។ មានបង្ហាញដូចខាងក្រោម:

-ប្រភេទត្រី ( ត្រីរ៉ស់ ត្រីដៀប-ឆ្តោ ត្រីក្រាញ់ ត្រីកន្ធរ ត្រីរៀល ត្រីលីញ ត្រីកំភ្លាញ ត្រីក្រុះ ត្រីឆ្លិន ត្រីច្រកែង ត្រីកាហែ ត្រីអំពិលទុំ ត្រីឆ្លាំង ត្រីសណ្តាយ ត្រីអណ្តែង ត្រីស្លាត ត្រីតាអោន ត្រីកេស ត្រីកញ្ចុះ ត្រីកំភ្លាវ ត្រីខ្ញីង ត្រីឆ្លូញ ត្រីដីរ ត្រីអណ្តាតឆ្កែ ត្រីកន្ទ្រង់ប្រេង ត្រីកញ្ចាញ់ច្រាស់ ត្រីច្រវាមូល ត្រីក្រាយ ត្រីទ្រនេល ត្រីក្រម៉ម ត្រីប្រា ត្រីពោរ ត្រីអន្ទង ត្រីកញ្ជូនជ័យ ត្រីកញ្ជ្រូក ត្រីខ្នាន់ ត្រីគ្រុំ ត្រីក្អែក ត្រីខ្នងវែង ត្រីស្លឹកឫស្សី ត្រីកន្ទាស់ភ្លុក ត្រីឆ្ពួត ត្រីស្រកាក្តាម ត្រីផ្ទោង ត្រីកំភ្លាញ់ទឹកបាយ ត្រីកំពត ត្រីព្រលូង ត្រីច្រឡឹង ត្រីឈ្កៀត ត្រីក្បាន្ត ត្រីអង្កត់ប្រាក់ ត្រីកន្ទ្រប់) ។

-ប្រភេទវារីសត្វ ( អណ្តើក កន្លាយ ក្រពើ ពស់ប្រលិត ពស់ត្រី ពស់ចាន់លួម ពស់ផ្ទក ពស់ឈើ ពស់សំលាប់កង្កែប ពស់ដែកចារ ពស់ថ្លាន់ ពស់វែករនាម ភេ ពស់វែកក្របី ខ្ទៅ.ខ្យង អន្សង លាស ក្តាម គ្រុំ កន្ធេះឡង់ កន្ធាលទូក) ។

-ប្រភេទរុក្ខជាតិព្រៃលិចទឹក ( កន្ទ្រៀង រាំង តាអូរ តាឡុក យ៉ាភ្លូង ផ្តៅ ផ្ទោល ច្រកែង ខ្ទុំ ល្បៀង អាទាំង ត្រសេក សណ្តាន់ រំដេញ ភ្លៃភ្លៀង បប្ញយ ប្របាច កុណ្តាប់ចង្កេរ ត្រដក់ ត្រស់ សង្សរ ថ្មើមអណ្តើក ទៀនព្រៃ ភ្នែកព្រាប បន្លាស្អិត ថ្កាលមាន់ ចង្កូមក្រពើ ឈ្លើយ រញ្ជៀ ឆ្អឹងពស់ ក្រពៅ ធ្មុងកញ្ចុះ ទ្រនុំអាអូត អញ្ចាញ បន្លាឃ្លៃ) ។

-ប្រភេទវារីរុក្ខជាតិ ( សារាយ ព្រលិត ត្រកួន ស្រងែ ចំបួង កំពីងពួយ ម្អមព្រៃ ស្លាបទា កន្ទ្រាំងហៃ កំប្លោក សួង ផ្តៅ វល្លិជ័រ វល្លិថ្កូវ វល្លិដូងព្រះ វល្លិត្រដិត ត្រែង ចក ស្នោ វល្លិប្រេង) ។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២១៤នាក់ ស្រីចំនួន ៧៨នាក់

-អ្នកមិនមែនជាសមាជិកសហគមន៍ជាអ្នកនេសាទចំនួន ៦៩៧ នាក់ ស្រីចំនួន៣៩២ នាក់

-អ្នកនេសាទមកពីក្រៅសហគមន៍ មានចំនួន ១៥០នាក់ ស្រីចំនួន ៦២ នាក់។ (អ្នកមកពីក្រៅសហគមន៍ភាគច្រើនមកពីព្រែកហ្លួង បាក់អំរែក ពាមសីមា ព្រែកត្រប់ អូរកំបុត ស្តី ទឹកជោរ...) ។

### ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូត របស់សមាជិកសហគមន៍នេសាទ :

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/ទំហំ/ប្រវែង(ម៉ែត្រ) | ចំនួនគ្រួសារ | ទំហំ/ប្រវែងសរុប | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ...) |
|---|---|---|---|---|---|
| សន្ទូច | សាង/២០០ផ្លែ | ២ | ២៥ | ៥០ | ០៩-១២ |
| មងរាយ | ដៃ/៤០ម | ១០ | ៣០ | ៣០០ | ១-៣ ដល់៧-១២ |
| លាន់ | គ្រ | ៥០ | ១៥ | ៧៥០ | ៧-៩ |
| ឡើ | គ្រ | ៥០ | ៥០ | ២៥០០ | ៨-១ |
| លបព្រៀង | គ្រ | ៣០ | ៥ | ១៥០ | ១ និង៧-៩ |
| លបលួង | គ្រ | ៣០ | ៣ | ៩០ | ៥-៧ |
| ឆក់ | គ្រ | ១ | ២៥ | ២៥ | ៣-៦ |
| បរ | ឡុក | ២ | ៣ | ៦ | ៨-១១ |
| ជូ | គ្រ | ២០ | ៧ | ១៤០ | ២-៦ |

| ប្រភេទទូកកាណូត | សមត្ថភាព/ទំហំ/ចំណុះ | ចំនួនគ្រួសារដែលមានទូក កាណូត | ចំនួនទូក កាណូត/គ្រួសារ គិតជាមធ្យម) | ចំនួន ទូកកាណូតសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ទូកអុំ | ៥ខ ០.៩ ខ ០.៣៥ | ៩៥ | ២ | ១៩០ | |
| កាណូតសាំង | ៥-១១សេះ | ៣០ | ១ | ៣០ | |
| កៅហ្លុង | -១២-១៦.៥សេះ | ៥ | ១ | ៥ | |
| | -២០សេះឡើង | ៥ | ១ | ៥ | |
| **សរុប** | | **១៣៥** | | **២៣០** | |

-ឧបករណ៍នេសាទ និងទូកការណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិក ក្នុងសហគមន៍នេសាទ និងអ្នកខាងក្រៅ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/ទំហំ/ប្រវែង(ម៉ែត្រ) | ចំនួនគ្រួសារ | ទំហំ/ប្រវែងសរុប | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ...) |
|---|---|---|---|---|---|
| សន្ទូច | សាង/២០០ផ្លែ | ២ | ៣០ | ៦០ | ០៩-១២ |
| មងរាយ | ដៃ/៤០ម | ១០ | ២០ | ២០០ | ១-៣ ដល់៧-១២ |
| លាន់ | គ្រ | ៥០ | ១០ | ៥០០ | ៧-៩ |
| ឡើ | គ្រ | ៥០ | ៥០ | ២៥០០ | ៨-១ |
| លបព្រៀង | គ្រ | ៣០ | ១៥ | ៤៥០ | ១ និង៧-៩ |
| លបលួង | គ្រ | ៣០ | ៥ | ១៥០ | ៥-៧ |
| ឆក់ | គ្រ | ១ | ៣០ | ៣០០ | ៣-៦ |
| បរ | ឡូក | ២ | ១ | ២ | ៨-១១ |
| ជួ | គ្រ | ២០ | ១០ | ២០០ | ២-៦ |

| ប្រភេទទូកកាណូត | សមត្ថភាព/ទំហំ/ចំណុះ | ចំនួនគ្រួសារដែលមានទូក កាណូត | ចំនួនទូក កាណូត/គ្រួសារ គិតជាម៉ែត្រ) | ចំនួន ទូកកាណូតសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ទូកអុំ | ៥x0.៥x0.៣៥ (១៥0គក) | ២០៤ | ២ | ៤០៨ | |
| កាណូតសាំង | ៥-១១សេះ | ៨៥ | ១ | ៨៥ | |
| កៅហ្វង | -១២-១៦.៥សេះ | 0 | ១ | ១0 | |
| | -២0សេះឡើង | ៧ | ១ | ៧ | |
| **សរុប** | | **២៩៦** | | **៥១០** | |

-ឧបករណ៍នេសាទ និងទូកការណូតរបស់អ្នកមិនមែនជាសមាជិក មកពីក្រៅសហគមន៍នេសាទ :

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/ទំហំ/ប្រវែង(ម៉ែត្រ) | ចំនួននាក់ | ទំហំ/ប្រវែងសរុប | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ...) |
|---|---|---|---|---|---|
| សន្ទូច | សាង/២00ផ្លែ | ៥ | ១០ | ៥០ | ០៧-១២ |
| មងរាយ | ដៃ/៤០ម | ២០ | ១៥ | ៣០០ | ៧-១១ |

| | | | | | |
|---|---|---|---|---|---|
| លបព្រៀង | គ្រ | ៥០ | ៣០ | ១ ៥០០ | ១ និង៧-៩ |
| លាន់ | គ្រ | ៥០ | ១០ | ៥០០ | ៧-៩ |
| ឆក់ | គ្រ | ១ | ៥០ | ៥០ | ៣-៥ |
| បរ | ឡូក | ២ | ៣ | ៦ | ៨-១១ |
| ឡើ | គ្រ | ៥០ | ៣០ | ១ ៥០០ | ៨-១ |

| **ឈ្មោះតំបន់ពាក់ពន្ធ័** | **ចំនួនអ្នកនេសាទមកពីក្រៅ** | **ចំនួនទូក -កាណូត** | | | |
|---|---|---|---|---|---|
| | | **ទូកអុំ/ចែវ** | **កាណូតកៅហ្វុង ១២ -១៦សេះ** | **កាណូតម៉ាស៊ីនសាំង ៥ -១១សេះ** | **កាណូតម៉ាស៊ីនចាប់ពី ២៥សេះឡើង** |
| ព្រៃកហ្លួង | ១៥ ស្រី០៣ | ៧ | ០ | ៧ | ០ |
| បាក់អំរែក | ៥ស្រី២ | ៥ | ៣ | ០ | ០ |
| ពាមសីមា | ២០ស្រី១០ | ១០ | ៣ | ៧ | ០ |
| ព្រៃកគ្រប់ | ៥ស្រី៣ | ៥ | ០ | ២ | ០ |
| អូរកំបុត | ២០ស្រី១០ | ១០ | ០ | ៩ | ០ |
| ស្តី | ១០ស្រី៥ | ៧ | ០ | ៣ | ០ |
| ទឹកជោរ | ១៥ស្រី៧ | ១០ | ០ | ១០ | ០ |
| **សរុប** | **៨៤ ស្រី៥២** | **៥៤** | **៦** | **៣៨** | **០** |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គ.ក្រ)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៩០០ គ | ៦២,៤៤គ | ៩៦២,៤៤ គ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ បាក់ព្រា មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយ សមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ០៩,១០ និងលេខ១១ កន្លែងនេសាទគ្រួសារដែលទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទកន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការ ចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធាន ធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើង ដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | សកម្មភាព | ពេលវេលា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន/ថ្ងៃ | | | |
| បឹងត្រស់ | មករា-មីនា | មងហ៊ុំ | ៣០x៥x០,០៥ | ២វង់ | -ផ្សព្វផ្សាយ | ខែមករា | រាល់ឆ្នាំ |
| | | ឡើ | | ១០០ | -ផ្លាកប្រកាស | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ |
| | | មងរាយ | ១ដៃ-៤០ម | ១០ដៃ | -ចុះល្បាត | ខែមករា-ខែកក្កដា | រាល់ឆ្នាំ |
| | | លាន់ | | ១០០បំពង់ | | | |
| បឹងតាទែន | មករា-មីនា | លបផ្សំព្រួល | ១,៥x០,៦ | ១៥គូ | -ផ្សព្វផ្សាយ | ខែមករា | រាល់ឆ្នាំ |
| | | មងរាយ | | ២០ដៃ | -ផ្លាកប្រកាស | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ |
| | | ឡើ | | ២០០ | -ចុះល្បាត | ខែមករា- | រាល់ឆ្នាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | ខែកក្កដា | |
| | | សន្ទូចរនង | | ១០០ផ្លែ | | | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ( ម) | ទំហំដែលត្រូវកែលំអ( ម) | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងត្រស់ | 100x50x0,7 | 30x20x1,5 | -ស្តារល្បាប់បឹង | ៤-២០០៩ | ៦-២០០៩ | |
| បឹងស្មោរ | 15x15x0,4 | 15x15x1,5 | -ស្តារល្បាប់បឹង | ៤-២០១០ | ៦-២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្រះវត្តបាក់ព្រា | 80x20x1 | ត្រីមេពូជ | -អប់រំផ្សព្វផ្សាយ | ១-២០០៨ | ១-២០០៨ | |
| | | | -ប្រជុំរៀបចំបទប្បញ្ញត្តិ | ២-២០០៨ | ២-២០០៨ | |
| | | | -ប្រជុំពិភាក្សា និងកំណត់ព្រំប្រទល់ | ៣-២០០៨ | ៣-២០០៨ | |
| | | | -ផ្លាកប្រកាស | ១-២០០៩ | ៣-២០០៩ | |
| | | | -រៀបចំស្តារ ស្រះអភិរក្ស ២០ម x ២០ម | ៤-២០០៨ | ៦-២០០៨ | |
| | | | -រៀបចំជម្រកត្រី | ៤-២០០៩ | ១០-២០០៩ | |
| | | | -ល្បាត | ១-២០០៨ | ១២-២០១០ | |
| -ទំនាបតាទែន | ១០០០ម x ១០០០ម | ព្រៃលិចទឹក | -អប់រំផ្សព្វផ្សាយ | ១-២០០៨ | ១-២០០៨ | |
| | | | -ប្រជុំរៀបចំបទប្បញ្ញត្តិ | ២-២០០៨ | ២-២០០៨ | |
| | | | -ប្រជុំពិភាក្សា និងកំណត់ព្រំប្រទល់ | ៣-២០០៨ | ៣-២០០៨ | |
| | | | -ផ្លាកប្រកាស | ១-២០០៩ | ៣-២០០៩ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | -កសាងខ្ទមអ្នកតា | ៣-២០០៩ | ៥-២០០៩ | |
| | | | -ធ្វើសារពើភ័ណ្ឌព្រៃ | ៤-២០០៩ | ៥-២០០៩ | |
| | | | -ធ្វើអនាម័យព្រៃ | ៣-២០១០ | ៦-២០១០ | |
| | | | -ធ្វើផ្លូវភ្លើង | ២-២០១០ | ៦-២០១០ | |
| | | | -ល្បាត | ១-២០០៨ | ១២-២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| -ទំនាបតាទែន | ២ហិកតា<br>៥ ០០០កូន | សណ្តាន់, ម្តេញ, ត្រសេក | -ការជ្រើសរើសអ្នកចូលរួម និងជ្រើសរើសគ្រាប់ | កញ្ញា-០៨ | តុលា-០៨ | |
| | | | -ការរៀបចំថ្នាលបណ្តុះកូនឈើ | មករា-០៩ | មករា-០៩ | |
| | | | -ដំណើរការបណ្តុះកូនឈើ | មករា-០៩ | មិថុនា-០៩ | |
| | | | -ការតាមដាន និងវាយតម្លៃ | មករា-០៩ | កក្កដា-០៩ | |
| | | | -យុទ្ធនាការដាំកូនឈើ | មិថុនា-០៩ | មិថុនា-០៩ | |
| -កន្លែងអភិរក្សត្រីមេពូជ ស្រះវត្តបាក់ព្រា | ២ហិកតា<br>៥ ០០០កូន | សណ្តាន់, ម្តេញ, ត្រសេក | -ការជ្រើសរើសអ្នកចូលរួម និងជ្រើសរើសគ្រាប់ | កញ្ញា-០៩ | តុលា-០៩ | |
| | | | -ការរៀបចំថ្នាលបណ្តុះកូនឈើ | មករា-១០ | មករា-១០ | |
| | | | -ដំណើរការបណ្តុះកូនឈើ | មករា-១០ | មិថុនា-១០ | |
| | | | -ការតាមដាន និងវាយតម្លៃ | មករា-១០ | កក្កដា-១០ | |
| | | | -យុទ្ធនាការដាំកូនឈើ | មិថុនា-១០ | មិថុនា-១០ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម :

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ការចិញ្ចឹមត្រី | ២០ បែរ | អណ្តែង | ៥០០០ក្បាល | ខែមិនា ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៩ |
| | ១០ បែរ | - | - | ខែមិនា ឆ្នាំ២០០៩ | ខែកុម្ភៈ ឆ្នាំ២០១០ |
| | ១០ បែរ | - | ៤០០០ក្បាល | ខែកុម្ភៈ ឆ្នាំ២០១០ | ខែធ្នូ ឆ្នាំ២០១០ |
| ការចិញ្ចឹមអន្ទង់ | ១០ បែរ | អន្ទង់ | ១០០គ.ក | ខែកក្កដា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៩ |
| | ១៥ បែរ | - | - | ខែកក្កដា ឆ្នាំ ២០០៩ | ខែមេសា ឆ្នាំ២០១០ |
| | ២០ បែរ | - | - | ខែកក្កដា ឆ្នាំ ២០១០ | ខែធ្នូ ឆ្នាំ២០១០ |

## គ -៦ -ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម ២០០៨-២០១០ | ថ្ងៃខែឆ្នាំបញ្ចប់ ២០០៨-២០១០ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយលក្ខន្តិកៈសហគមន៍ | ២១៦នx១៥០០ ៛ | ២១៦នx១៥០០៛ | ៣២៤០០០៛ x ៣ឆ្នាំ | ៩៧២០០០៛ |

## គ -៧ -ផែនការពង្រីកមុខរបរចិញ្ចឹមជីវិត

ផែនការពង្រីកមុខរបរចិញ្ចឹមជីវិត ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

| ប្រភេទមុខរបរ | ចំនួនគ្រួសារ | ទំហំផលិតកម្មក្នុងមួយគ្រួសារ | ទំហំផលិតកម្មសរុប | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| បណ្តុះផ្សិត | ១០ | ៥រង(១រង-៣ម) | ៥០ | ខែមិនា ឆ្នាំ២០០៨ | ខែឧសភា |

| | | | | | |
|---|---|---|---|---|---|
| | | | | | ឆ្នាំ ២០០៨ |
| | ៥ | - | ២៥ | ខែមិនា ឆ្នាំ ២០០៩ | ខែឧសភា ឆ្នាំ២០០៩ |
| ចិញ្ចឹមជ្រូក | ៣០ | ៤ក្បាល | ១២០ | ខែមករា ឆ្នាំ ២០០៨ | ខែតុលា ឆ្នាំ២០០៨ |
| | ១០ | - | ៤០ | ខែមករា ឆ្នាំ២០០៩ | ខែតុលា ឆ្នាំ២០០៩ |
| | ៥ | - | ២០ | ខែមករា ឆ្នាំ២០១០ | ខែតុលា ឆ្នាំ២០១០ |
| ចិញ្ចឹមមាន់ | ៥០ | ៥ក្បាល | ២៥០ | ខែមេសា ឆ្នាំ២០០៨ | ខែតុលា ឆ្នាំ២០០៨ |
| | ២០ | - | ១០០ | ខែមេសាឆ្នាំ២០០៩ | ខែតុលា ឆ្នាំ២០០៩ |
| | ១០ | - | ៥០ | ខែមេសា ឆ្នាំ២០១០ | ខែតុលា ឆ្នាំ២០១០ |

## គ-៤-ផែនការពង្រឹងសមត្ថភាព

ផែនការពង្រឹងសមត្ថភាពត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| សកម្មភាព | ចំនួនអ្នកចូលរួម | រយៈពេល | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | -២០នាក់ | -២ថ្ងៃ( ៣ដង) | -ខែកុម្ភៈ | -ខែកុម្ភៈ | រាល់ឆ្នាំ |
| -បណ្តុះបណ្តាលបច្ចេកទេស បណ្តុះផ្សិត | -១០នាក់ | -១ថ្ងៃ(២ដង) | -ខែមិនា | -ខែមិនា | ឆ្នាំ២០០៨, ០៩ |
| -បណ្តុះបណ្តាលកិច្ចការរដ្ឋបាល | -១០នាក់ | -២ថ្ងៃ( ១ដង) | -ខែមករាឆ្នាំ០៨ | -ខែមករាឆ្នាំ០៨ | |
| -បណ្តុះបណ្តាលជីអ៊ីអឹម | -១០នាក់ | -១ថ្ងៃ(២ដង) | -ខែមេសា | -ខែមេសា | ឆ្នាំ២០០៨, ០៩ |
| -បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | -១៥នាក់ | -១ថ្ងៃ | -ខែកក្កដា ឆ្នាំ២០០៨ | -ខែកក្កដា ឆ្នាំ២០០៨ | |
| -បណ្តុះបណ្តាលជំនួញខ្នាតតូច | -១៥នាក់ | ១ថ្ងៃ | -ខែមេសា ឆ្នាំ២០១០ | -ខែមេសា ឆ្នាំ២០១០ | |
| -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជន្លេន | -១៥នាក់ | ១ថ្ងៃ | -ខែមករា ឆ្នាំ២០០៩ | -ខែមករា ឆ្នាំ២០០៩ | |

| | | | | | |
|---|---|---|---|---|---|
| -បណ្តុះបណ្តាលបច្ចេកទេស បណ្តុះ និងដាំព្រៃលិចទឹក | ២០នាក់ | ២ថ្ងៃ | -ខែកក្កដា ឆ្នាំ២០០៨ | -ខែកក្កដា ឆ្នាំ២០០៨ | |
| -បណ្តុះបណ្តាលបច្ចេកទេសធ្វើសារពើភ័ណ្ឌព្រៃ | -១៥នាក់ | ១ថ្ងៃ | -ខែកុម្ភៈ ឆ្នាំ២០១០ | -ខែកុម្ភៈ ឆ្នាំ២០១០ | |
| -ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធ | -២៥០នាក់ | ៦ដង | -ខែតុលា និងខែមករា | -ខែតុលា និងខែមករា | រាល់ឆ្នាំ |
| -សិក្ខាសាលាថ្នាក់ភូមិ ស្តីពី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ២០នាក់ | ២ថ្ងៃ | ខែកក្កដាឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| -ទស្សនៈកិច្ច សិក្សាក្រៅខេត្ត | -១០នាក់ | -៣ថ្ងៃ | -ខែ៤មេសា ឆ្នាំ២០១០ | -ខែមេសា ឆ្នាំ២០១០ | |
| -ទស្សនៈកិច្ច សិក្សាក្នុងខេត្ត | -១៥នាក់ គុណ២ | -៣ថ្ងៃ គុណ២ | -ខែវិច្ឆិកា ឆ្នាំ២០០៨, ០៩ | -ខែវិច្ឆិកា ឆ្នាំ២០០៨, ០៩ | |
| -បណ្តុះបណ្តាលស្តីពីការសរសេរគម្រោងស្នើសុំ | -១៥នាក់ | ២ថ្ងៃ | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |

### គ-៩- ផែនការចងក្រងក្រុមស្ត្រី

ផែនការចងក្រងក្រុមស្ត្រីត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ប្រភេទក្រុម | ទំហំ | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| -ក្រុមសន្សំ | ១០នាក់ (មួយក្រុម) | -ផ្សព្វផ្សាយរកអ្នកចូលរួម | -ខែមករា ឆ្នាំ២០០៨ | -ខែមករា ឆ្នាំ២០០៨ | |
| | | -រៀបចំច្បាប់ លក្ខន្តិកៈ | -ខែមិនា ឆ្នាំ២០០៨ | -ខែមិនា ឆ្នាំ២០០៨ | |
| | | -រៀបចំរចនាសម្ព័ន្ធរបស់ក្រុម | -ខែមេសា ឆ្នាំ២០០៨ | -ខែមេសា ឆ្នាំ២០០៨ | |

### គ-១០- ផែនការពង្រឹងការគ្រប់គ្រង

ផែនការពង្រឹងសមត្ថភាពត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| សកម្មភាព | ទំហំ | ចំនួន | ចាប់ផ្តើម | បញ្ចប់ | ផ្សេង |
|---|---|---|---|---|---|
| -ស្នាក់ការសហគមន៍នេសាទ | ៧មx ៦ម | ០១ខ្នង | ខែកក្កដា | ខែសីហា | -បណ្តែតទឹក |

| | | | | | |
|---|---|---|---|---|---|
| | | | ឆ្នាំ២០០៩ | ឆ្នាំ២០០៩ | -ប្រក់សង្កសី |
| -ទូកអុំ | ៥មx ១.២មx 0.៥ម | ០១គ្រឿង | ខែមិនា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៨ | |
| -ទូកចែវ | ៧មx ១.៥មx 0.៥ម | ០១គ្រឿង | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកក្កដា ឆ្នាំ២០១០ | |
| -កាណូត | ៧មx ១.៥មx 0.៧ម | ០១គ្រឿង | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកក្កដា ឆ្នាំ២០១០ | ម៉ាស៊ីន ២៥សេះ |
| -អាវភ្លៀង | | ២០សម្រាប់ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| -អង្រឹង | | ២០សម្រាប់ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| -ប៉ាណូ | ៣មx ២ម | ០១ផ្ទាំង | ខែមករា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | ធ្វើពីដែក មានជើងទ្រ |
| -ល្បាត | ៣ដង/ខែx ៣៦ | ១០៨ដង | ខែមករា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | ម្តង៥-៦នាក់ |
| -ប្រជុំគណៈកម្មការតាមដានការអនុវត្តផែនការ | | ២ដង/ឆ្នាំ | -ខែមិថុនា និងធ្នូ ឆ្នាំ២០០៨,០៩, ១០ | -ខែមិថុនា និងធ្នូ ឆ្នាំ២០០៨,០៩, ១០ | |
| -ប្រជុំប្រចាំខែ | ១ដង x៣៦ខែ | ៣៦ដង | ២០០៨ | ២០១០ | រាល់ចុងខែ |

### ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

-បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រីការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់

-ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូរសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍

-ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ចាក់ព្រា រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ១-១-ផ្សព្វផ្សាយជាសាធារណៈ តាមឧឃោសនសព្ទពីការសាកល្បងរក្សា ទុកបឹងត្រស់ និងបឹងតាទែន ដាក់ឱ្យមានការគ្រប់គ្រងច្បាស់លាស់ | -ប្រជានេសាទយ៉ាងហោចណាស់៨៥% គាំទ្រយន្តការ<br>-បឹងចំនួន០២ នឹងមានការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព | ១២០ ០០០រៀល | សហគមន៍នេសាទ | ខែមករា | ខែមករា | រាល់ឆ្នាំ |
| | ១-២-រៀបចំផ្លាកសញ្ញា ដែលចែងអំពីយន្តការគ្រប់គ្រង | -ប្រជានេសាទ នឹងចូលរួមគោរពតាមការណែនាំ<br>-ផ្លាកធ្វើអំពីដែកចំនួន ពីរផ្ទាំងនឹងតាំងឡើង ត្រង់ច្រកចេញចូល នៃបឹងទាំងពីរ | ៣០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សប្បុរសជន . | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ | |
| | ១-៣-ការយាមល្បាត ពង្រឹងការគ្រប់គ្រងបឹងទាំងពីរ | -ក្រុមល្បាតដែលមានគ្នាយ៉ាងតិច៥នាក់ ចូលរួមល្បាត ៤ដងក្នុងមួយខែ<br>-ការគ្រប់គ្រង មានដំណើរការរលូន និងមានបន្សល់ត្រីពូជ | ២ ៤០៤ ៨០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា | ខែកក្កដា | រាល់ឆ្នាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ក្នុងបឹងនិមួយៗ | | | | | |
| ២- ការកែលំអដែនសាទ | ២-១-ស្តារបឹងត្រស់ និងបឹងស្នោ ដោយប្រើកំលាំងពលកម្ម | -ល្បាប់បាតបឹង ចំនួន១ ២៥០ម³ ដែលមានជម្រៅ ១,៥ម ត្រូវស្តារមកខ្ពងមាត់បឹង<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រី ត្រូវកែលំអ | ៦ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមេសា ឆ្នាំ២០០៩ និង២០១០ | ខែមិថុនា ឆ្នាំ២០០៩ និង២០១០ | |
| ៣- ការកំណត់ និងរៀបចំតំបន់អភិរក្ស | ៣-១-ប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ដើម្បីបង្កើតកន្លែងអភិរក្សត្រីមេពូជ និងព្រៃលិចទឹក | -ស្រះវត្តបាក់ព្រា បណ្តោយ ៨០ម ទទឹង២០ម និងព្រៃទំនាបតាទែន បណ្តោយ ១ ០០០ម ទទឹង ១ ០០០ម ទទួលការឯកភាពរក្សាទុកជាកន្លែងអភិរក្ស<br>-អ្នកចូលរួម យ៉ាងតិច២០នាក់ នឹងបានយល់កាន់ តែច្បាស់ពីអត្ថប្រយោជន៍នៃការបង្កើតកន្លែងអភិរក្ស | ៦០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |
| | ៣-២-ប្រជុំរៀបចំបទបញ្ញត្តិ និងគោលការណ៍គ្រប់គ្រង | -សហគមន៍ និងអ្នកពាក់ព័ន្ធ យ៉ាងតិច២០នាក់ ចូលរួម | ៦០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កន្លែងអភិរក្ស | ពិភាក្សា និងផ្តល់យោបល់<br>-យន្តការគ្រប់គ្រង នឹងត្រូវបាន កំណត់ច្បាស់លាស់ និងមានការ ទទួលខុសត្រូវ | | | | | |
| | ៣-៣-ការប្រជុំពិភាក្សា និង ចុះកំណត់ព្រំប្រទល់កន្លែង អភិរក្ស | -ទីតាំងសំខាន់ៗនៃព្រំប្រទល់ កន្លែងអភិរក្ស ត្រូវបានកំណត់ និងដៅច្បាស់លាស់<br>-បង្គោល និងផ្លាកសញ្ញា សំគាល់ព្រំប្រទល់ ត្រូវបានដាក់ នៅនឹងកន្លែង | ១៧៧ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ នេសាទ | ខែមិនា ឆ្នាំ២០០៨ | ខែមិនា ឆ្នាំ២០០៨ | |
| | ៣-៤-រៀបចំផ្ទាំងប៉ាណូ ផ្សព្វផ្សាយកន្លែងអភិរក្ស | -ផ្ទាំងប៉ាណូ ធ្វើអំពីដែក បណ្តោយ២,៥ម ទទឹង១,៨ម ចំនួន០២ផ្ទាំង នឹងត្រូវដាក់តាំង តាមច្រកសំខាន់ៗ<br>-ប្រជាពលរដ្ឋយល់ និងចូលរួម គ្រប់គ្រងកន្លែងអភិរក្ស | ២ ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមករា ឆ្នាំ២០០៩ | ខែមិនា ឆ្នាំ២០០៩ | |
| | ៣-៥-ការជីកស្តារស្រះកន្លែង អភិរក្សត្រីមេពូជ | -ល្បាប់បាតស្រះ ប្រវែង២០ម ដែលមានទទឹង២០ម និង | ៤ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមេសា ឆ្នាំ២០០៨ | ខែមិថុនា ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ជម្រៅ ១ម ត្រូវស្តារមកខ្ទង់ស្រះ<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រីត្រូវកែលំអ | | | | | |
| | ៣-៦-ការរៀបចំធ្វើជម្រកត្រីក្នុងកន្លែងអភិរក្ស | -គល់ឈើ ១៥គល់ បង្គោលថ្ម ១០ដើម និងលូស៊ីម៉ង់ ២០លូ ត្រូវបានដាក់ក្នុងកន្លែង អភិរក្ស<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រីត្រូវកែលំអ ជាសំបុកពងកូន និងទីសុវត្ថិភាព | ៦៩៦ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៩ | ខែតុលា ឆ្នាំ២០០៩ | |
| | ៣-៧-ការធ្វើសារពើភ័ណ្ឌព្រៃលិចទឹក | -សមាសភាព ប្រភេទ ចំនួន ដង់ស៊ីតេ រុក្ខជាតិព្រៃលិចទឹក ត្រូវបានកត់ត្រា<br>-កំណត់បានយន្តការគ្រប់គ្រងព្រៃបានត្រឹមត្រូវ | ៧៨០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៩ | ខែឧសភា ឆ្នាំ២០០៩ | |
| | ៣-៨-ការរៀបចំធ្វើអនាម័យព្រៃលិចទឹក | -ប្រភេទរុក្ខជាតិ ចង្រៃ ត្រូវបានបំផ្លាញចោល<br>-រុក្ខជាតិព្រៃលិចទឹក មានសុខ- | ១ ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០១០ | ខែមិថុនា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ភាពល្អ និងសុវត្ថិភាព | | | | | |
| | ៣-៩-ការរៀបចំធ្វើផ្លូវការ-ពារភ្លើងឆេះព្រៃអភិរក្ស | -របាំងការពារការរាលដាលភ្លើងឆេះព្រៃ ត្រូវបានបង្កើតឡើង ដែលមានប្រវែង២ ០០០ម ទទឹង៥ម | ៤ ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ ឆ្នាំ២០១០ | ខែមិថុនា ឆ្នាំ២០១០ | |
| | ៣-១០-កសាងខ្ទមអ្នកតា | -ខ្ទមអ្នកតា បណ្តោយ៣ម ទទឹង២ម និងកំពស់៣,៥ម ត្រូវបានកសាង ជាទីសក្ការៈ<br>-ព្រៃលិចទឹក ត្រូវបានគោរពថែរក្សា និងស្រឡាញ់ ដូចអ្នកតា | ១ ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០០៩ | ខែឧសភា ឆ្នាំ២០០៩ | សង់អំពីឈើ ខ្ពស់ផុតពីទឹក |
| | ៣-១១-ការចុះល្បាតកន្លែងអភិរក្ស | -បទល្មើសនេសាទក្នុងកន្លែងអភិរក្សថយចុះ ៨០%<br>-ក្រុមល្បាតយ៉ាងហោច ៥នាក់ក្នុងមួយក្រុម ចុះល្បាត៣ដងក្នុងមួយខែ | ៦ ០៥១ ២០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| ៤-ការបណ្តុះ និងដាំព្រៃ | ៤-១-ការជ្រើសរើស | -យ៉ាងហោចប្រជាពលរដ្ឋ ២០ | ៤០០ ០០០រៀល | គំរោង, អង្គការ, | ខែកញ្ញា | ខែតុលា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| លិចទឹក ដែលផ្តល់ផ្លែ ហូបបាន | អ្នកចូលរួម និងជ្រើសរើស គ្រាប់ | គ្រួសារ ចូលរួមកម្មវិធី បណ្តុះ កូនឈើ<br>-គ្រាប់ឈើប្រភេទសណ្តាន់ ត្រសេក និងម្តេញ ត្រូវបាន ប្រមូលទុក | | ឃុំ, សហគមន៍ នេសាទ | ឆ្នាំ២០០៨ ,២០០៩ | ឆ្នាំ២០០៨, ២០០៩ | |
| | ៤-២-ការរៀបចំថ្នាលបណ្តុះ កូនឈើ | -ថ្នាលបណ្តុះកូនឈើ ទំហំ ៤ម គុណ ៣ម ចំនួន ២០ កន្លែង ត្រូវបានកសាងឡើង<br>-ដី ត្រូវបានប្រមូលច្រកថង់ ចំនួន ២៥០ថង់ នៅតាមថ្នាល និមួយៗ | ១៣០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ នេសាទ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែមករា ឆ្នាំ២០០៩ ២០១០ | |
| | ៤-៣-ដំណើរការបណ្តុះ កូនឈើ | -គ្រាប់ឈើ ត្រូវបានដាក់ទៅ ក្នុងថង់ តាមថ្នាលគ្រួសារ<br>-កូនឈើ ចំនួន ៥ ០០០ដើម ត្រូវដុះចេញ និងលូតលាស់ ជា បន្តបន្ទាប់ | ៨០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ នេសាទ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | |
| | ៤-៤-ការតាមដាន និង វាយតម្លៃ | -កំរិតលូតលាស់កូនឈើ ត្រូវ បានតាមដាន និងកត់ត្រា | ៨០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែកក្កដា ឆ្នាំ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | -ចំណុចខ្សោយ ត្រូវបានកែលំអ | | នេសាទ | | ២០១០ | |
| | ៤-៥-យុទ្ធនាការដាំកូនឈើ | -សមត្ថកិច្ចពាក់ព័ន្ធ និង សមាជិកសហគមន៍នេសាទយ៉ាងតិច ចំនួន ១០០នាក់ ចូលរួម ដាំកូនឈើព្រៃលិចទឹក<br>-កូនឈើចំនួន ១០ ០០០ដើម ត្រូវបានដាក់ដាំលើផ្ទៃដីទំហំ ៤ ហិកតា | ៨០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | |
| ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ៥-១-ចិញ្ចឹមត្រីអណ្តែង | -យ៉ាងតិចត្រីអណ្តែង ៤០ត្រើង នឹងត្រូវ ដាក់ចិញ្ចឹម ដែលមួយត្រើង មាន កូនត្រី ៥ ០០០ក្បាល<br>-វារីវប្បករ នឹងរកបានប្រាក់ចំណូលបន្ថែម សម្រាប់គ្រួសារ | ៥២០ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| | ៥-២-ចិញ្ចឹមអន្ទង់ | -យ៉ាងតិច អន្ទង់៤៥ត្រើង នឹងត្រូវ ដាក់ចិញ្ចឹម ដែលមួយត្រើង មាន អន្ទង់ ១០០គ.ក្រ<br>-វារីវប្បករ នឹងរកបានប្រាក់ | ៥២ ៥០០ ០០០រៀល | គំរោង; អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ចំណូលបន្ថែម សម្រាប់គ្រួសារ | | | | | |
| ៦-ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍ | ៦-១-ភាគទានពីសមាជិកសហគមន៍ចូលថ្មី | ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មីចំនួន៥០នាក់ ក្នុង ១ឆ្នាំ | ៣៧៥.០០០ រៀល | សហគមន៍នេសាទ | ២០០៨ | ២០១០ | |
| | ៦-២-ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍និងចូលរួមបង់ភាគទានប្រចាំឆ្នាំរៀលរាល់ឆ្នាំ | ៩៧២០០០រៀល | សហគមន៍នេសាទ | ២០០៨ | ២០១០ | |
| ៧-ផែនការអភិវឌ្ឍន៍មុខរបរ ក្នុងចំណោមសមាជិកសហគមន៍នេសាទ | ៧-១-ការចិញ្ចឹមជ្រូក | -យ៉ាងតិច មានគ្រួសារ ចំនួន ៤៥ បានដាក់ជ្រូកចិញ្ចឹម ក្នុងរយៈពេលបីឆ្នាំ ដែលមានកូនជ្រូក០៤ក្បាល ក្នុងមួយគ្រួសារ<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់គ្រួសារបន្ថែម | ១ ៩០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែតុលា ឆ្នាំ២០១០ | |
| | ៧-២-ការចិញ្ចឹមមាន់ | -យ៉ាងតិច មានគ្រួសារ ចំនួន ៨០ បានដាក់មាន់ចិញ្ចឹម ក្នុងរយៈពេលបីឆ្នាំ ដែលមានមេមាន់ ០៥ក្បាល ក្នុងមួយគ្រួសារ<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់ | ២២៥ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨ | ខែតុលា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | គ្រួសារបន្ថែម | | | | | |
| | ៧-៣-ការបណ្តុះផ្សិត ជាលក្ខណៈគ្រួសារ | -យ៉ាងតិច មានគ្រួសារ ១៥ បានទទួលវគ្គបណ្តុះបណ្តាល និងរៀបចំរងបណ្តុះផ្សិត មួយគ្រួសារ ៥រង<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់គ្រួសារបន្ថែម | ៩០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០០៨, ០៩ | ខែឧសភា ឆ្នាំ២០០៨, ០៩ | |
| ៨-ផែនការពង្រឹងសមត្ថភាព សហគមន៍នេសាទ | ៨-១-ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | -វគ្គបណ្តុះបណ្តាលចំនួន ០៣ ដែលមានប្រជាពលរដ្ឋ ២០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេសចិញ្ចឹមត្រី<br>-ចលនាចិញ្ចឹមត្រីមានសន្ទុះកើនឡើង | ១ ៩៧០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ | ខែកុម្ភៈ | រាល់ឆ្នាំ |
| | ៧-២-ការបណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត | -វគ្គបណ្តុះបណ្តាលចំនួន ០២ ដែលមានប្រជាពលរដ្ឋ ១០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេស | ១ ០២០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០០៨, ២០០៩ | ខែមិនា ឆ្នាំ២០០៨, ២០០៩, | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | បណ្ដុះផ្សិត<br>-ចលនាបណ្ដុះផ្សិតមានសន្ទុះកើនឡើង | | | | | |
| | ៧-៣-ការបណ្ដុះបណ្ដាលបច្ចេកទេសធ្វើជី អ៊ី អឹម | -វគ្គបណ្ដុះបណ្ដាលចំនួន ០២ ដែលមានប្រជាពលរដ្ឋ ១០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេសផលិតជី អ៊ី អឹម<br>-កាកសំណល់ត្រូវបានកែប្រែជា ជី អ៊ី អឹម ដែលប្រើសម្រាប់ទប់ស្កាត់ជំងឺត្រី និងជម្រុញការលូតលាស់របស់ត្រី | ១ ០២០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨, ២០០៩ | ខែមេសា ឆ្នាំ២០០៨, ២០០០៩ | |
| | ៨-៤-បណ្ដុះបណ្ដាល បច្ចេកទេសបណ្ដុះកូនឈើ | -ប្រជាពលរដ្ឋ ២០នាក់ បានយល់ដឹងពីសារៈប្រយោជន៍ព្រៃលិចទឹក និងបច្ចេកទេសដាំដុះ<br>-កូនឈើព្រៃលិចទឹកនឹងបានបណ្ដុះនៅតាមថ្នាល ប្រចាំគ្រួសារ | ៦០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៨-៥-បណ្តុះបណ្តាលកិច្ចការរដ្ឋបាល | -វគ្គបណ្តុះបណ្តាលចំនួន ០១ ដែលមានប្រជាពលរដ្ឋ ១៥នាក់ក្នុងមួយវគ្គ ទទួល បានការយល់ដឹងពីកិច្ចការរដ្ឋបាល<br>-ដំណើរការគ្រប់គ្រងរបស់សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | ៩៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |
| | ៨-៦-បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | -គណៈកម្មការសហគមន៍ទាំង៩នាក់ រួម អ្នកពាក់ព័ន្ធ ៥នាក់ ទទួលការយល់ដឹងពីកាតព្វកិច្ច និងភារកិច្ច របស់អ្នកដឹកនាំ<br>-សហគមន៍មានដំណើរការល្អ | | | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| | ៨-៧-បណ្តុះបណ្តាលជំនួញខ្នាតតូច | -មានគំនិតថ្មីៗប្រឹតមុខរបរបន្ថែម ក្រៅពីនេសាទ<br>-យ៉ាងតិច ប្រជាពលរដ្ឋ ២០នាក់ រួមទាំងគណៈកម្មការបានទទួលការយល់ដឹង | | | ខែមេសា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៨-៨-បណ្តុះបណ្តាលការចិញ្ចឹមជន្លេន | -សមាជិកសហគមន៍ និងគណៈកម្មការ យ៉ាងតិច២០នាក់ត្រូវបណ្តុះបណ្តាល និងក្លាយជាគ្រូបង្គោល<br>-មានប្រជាពលរដ្ឋ យ៉ាងតិច ៥០% នៃអ្នកបានរៀល អនុវត្តការចិញ្ចឹមជន្លេន | | | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ | |
| | ៨-៩-បណ្តុះបណ្តាលបច្ចេកទេស ធ្វើសារពើភ័ណ្ឌព្រៃលិចទឹក | -សមាជិកសហគមន៍ និងគណៈកម្មការ យ៉ាងតិច២០នាក់ត្រូវបណ្តុះបណ្តាល និងក្លាយជាអ្នកអនុវត្តជាក់ស្តែង<br>-ព្រៃលិចទឹកត្រូវបានធ្វើសារពើភ័ណ្ឌ ចូលបញ្ជី | | | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកុម្ភៈ ឆ្នាំ២០១០ | |
| | ៨-១០-ការផ្សព្វផ្សាយជាសាធារណៈ នូវចំណុចសំខាន់ៗ នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | -ប្រជានេសាទយ៉ាងតិច៥០% បានដឹង និងឮ ជារៀងរាល់ឆ្នាំ ពីវិធានការគ្រប់គ្រងរបស់សហគមន៍<br>-ដំណើរការគ្រប់គ្រងរបស់ | ៣០០ ០០០រៀល | សហគមន៍នេសាទ | ខែមករា, តុលា | ខែមករា, តុលា | រាល់ឆ្នាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | | | | | |
| | ៨-១១-សិក្ខាសាលាថ្នាក់ភូមិស្តីពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ថ្នាក់ដឹកនាំសហគមន៍ អង្គភាពពាក់ព័ន្ធ និងសមាជិកសហគមន៍នេសាទយ៉ាងតិច២០នាក់ បានយល់ ពីវិធានការគ្រប់គ្រងរបស់ សហគមន៍<br>-ដំណើរការគ្រប់គ្រងរបស់សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| | ៨-១២-ទស្សនកិច្ចសិក្សា ក្នុងខេត្ត | -ចំណេះដឹង និងបទពិសោធន៍ត្រូវបានផ្លាស់ប្តូរ និងកែលំអចំនួន ២លើក ដែលមានអ្នកចូលរួម សរុបចំនួន ១៥នាក់<br>-មានសកម្មភាពថ្មី ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលនៃការធ្វើទស្សនកិច្ច | ២ ២២០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែវិច្ឆិកា ឆ្នាំ២០០៨, ២០០៩ | ខែវិច្ឆិកា ឆ្នាំ២០០៨, ២០០៩ | |
| | ៨-១៣-ទស្សនកិច្ចសិក្សា | -ចំណេះដឹង និងបទពិសោធន៍ | ៣ ១០០ ០០០រៀល | គំរោង, អង្គការ, | ខែមេសា | ខែមេសា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ក្រៅ ខេត្ត | ត្រូវបានផ្លាស់ប្តូរ និងកែលំអ ចំនួន ១លើក ដែលមានអ្នកចូលរួម សរុបចំនួន ១០នាក់<br>-មានសកម្មភាពថ្មី ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលនៃការធ្វើទស្សនកិច្ច | | ឃុំ, សហគមន៍នេសាទ | ឆ្នាំ២០១០ | ឆ្នាំ២០១០ | |
| | ៨-១៤-បណ្តុះបណ្តាលស្តីពីការសរសេរគម្រោងស្នើសុំ | -គណៈកម្មការសហគមន៍, សមាជិកសកម្ម មេភូមិ សរុបចំនួន ១៥នាក់ ទទួលបានការបណ្តុះបណ្តាល<br>-សហគមន៍ ធ្វើសំណើរសុំថវិកាពីម្ចាស់ជំនួយ ដើម្បីអនុវត្តផែនការរបស់ខ្លួន | ៦០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |
| ៩-ការចងក្រងក្រុមស្ត្រី | ៩-១-ការជ្រើសរើសស្ត្រីស្ម័គ្រចិត្តចងក្រងជាក្រុមទុនបង្វិល | -ស្ត្រី ចំនួន ១០នាក់ស្ម័គ្រចិត្តចូលរួមចងក្រងជាក្រុម<br>-ផ្តល់ឱកាសឱ្យស្ត្រី ចេះជួយគ្នាទៅវិញទៅមក<br>-ផ្តល់ឱកាសឱ្យស្ត្រី មានទុន | | | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រកបមុខរបរចិញ្ចឹមជីវិត | | | | | |
| | ៩-២-ការប្រជុំពិភាក្សារៀបចំច្បាប់របស់ក្រុម | -វិធានទាំងឡាយត្រូវបង្កើតឡើងដើម្បីសម្រួលដល់ដំណើរការប្រព្រឹត្តិទៅនៃ ក្រុម | ៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០០៨ | ខែមិនា ឆ្នាំ២០០៨ | |
| | ៩-៣-ការរៀបចំរចនាសម្ព័ន្ធរបស់ ក្រុម | -ក្រុមមានថ្នាក់ដឹកនាំ ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីសមាជិកក្រុម និងសហគមន៍ទាំងមូល | ៣០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៨ | |
| ១០-ផែនការពង្រឹងការគ្រប់គ្រងរបស់សហគមន៍នេសាទ | ១០-១-ការកសាងទីស្នាក់ការសហគមន៍ | -ផែបណ្តែតទឹក ទំហំ៧ម គុណ ៦ម ធ្វើពីឈើ ប្រក់សង្កសីត្រូវបង្កើតឡើង<br>-ស្នាក់ការនឹងក្លាយជាទីតាំងសម្រួលឱ្យការគ្រប់គ្រង និងបណ្តុះបណ្តាល របស់សហគមន៍ | ៨ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៩ | ខែសីហា ឆ្នាំ២០០៩ | |
| | ១០-២-ទិញទូកអុំ ចំនួន ០១ គ្រឿង ទំហំ ៥មគុណ ១,២ម | -មានមធ្យោបាយសម្រាប់ចុះល្បាត កន្លែងនេសាទសហគមន៍ | ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិនា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៨ | |
| | ១០-៣-ទិញទូកចែវ ចំនួន០១ | -មានមធ្យោបាយសម្រាប់ចុះ | ១ ២០០ ០០០រៀល | គំរោង, អង្គការ, | ខែកុម្ភៈ | ខែកក្កដា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គ្រឿង ទំហំ៧មគុណ១,៥ម | ល្បាត កន្លែងនេសាទសហគមន៍ | | ឃុំ, សហគមន៍នេសាទ | ឆ្នាំ២០១០ | ឆ្នាំ២០១០ | |
| | ១០-៤-កាណូត ទំហំ៧មគុណ១,៥ម ម៉ាស៊ីន ៣ឡុក | -មានមធ្យោបាយសម្រាប់ចុះល្បាត កន្លែងនេសាទសហគមន៍ | ២ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកក្កដា ឆ្នាំ២០១០ | |
| | ១០-៥-ទិញអាវភ្លៀង | -ក្រុមល្បាតមានអាវការពារភ្លៀង ទប់ស្កាត់ជំងឺដង្កាត់ផ្សេងៗ | ១៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| | ១០-៦-អង្រឹង | -ក្រុមល្បាតមានអង្រឹងដេកហើយអាចការពារ សត្វខាំ ទប់ស្កាត់ជំងឺដង្កាត់ផ្សេងៗ | ៤៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| | ១០-៧-ប៉ាណូផ្សព្វផ្សាយដាក់ក្នុងភូមិ | -ប្រជាពលរដ្ឋកាន់តែយល់ច្បាស់ពីអត្ថប្រយោជន៍ធនធានធម្មជាតិ និងការហាមឃាត់ផ្សេងៗ<br>-ប៉ាណូធ្វើអំពីដែក មានគូររូបភាព ទំហំ ៣ម គុណ២,៥ម កំពស់២ម ត្រូវបានដាក់ចំទី | ១ ២០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រជុំជនភូមិ | | | | | |
| | ១០-៨-ការចុះល្បាត ក្នុងកន្លែង នេសាទសហគមន៍ | -បទល្មើសនេសាទ ត្រូវថយចុះយ៉ាងតិច៧០%<br>-ច្បាប់ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ ត្រូវបានអនុវត្ត | ៨ ៧៤៨ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| | ១០-៩-ប្រជុំគណៈកម្មការ តាម ដានអនុវត្ត ការផែនការ | -គណៈកម្មការតាមដាន និងជម្រុញ ត្រូវបង្កើតឡើង<br>-មានតម្លាភាព ក្នុងការអនុវត្ត | | | ខែមិថុនា ឆ្នាំ២០០៨, ០៩,១០ | ខែធ្នូ ឆ្នាំ២០០៨, ០៩,១០ | |
| | ១០-១០-ការប្រជុំប្រចាំខែ | -សមិទ្ធផល ត្រូវបង្ហាញ<br>-ចំណុចខ្សោយ ត្រូវលុបបំបាត់<br>-ផែនការអនុវត្តបន្ត ត្រូវរៀបចំឡើង | | | ២០០៨ | ២០១០ | រាល់ខែ |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ២០០៨ | | | | | | | | | | | | ឆ្នាំ២០០៩ | | | | | | | | | | | | ឆ្នាំ២០១០ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១-១ | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | |
| ១-២ | | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | | | | |
| ១-៣ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ២-១ | | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៣-១ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-២ | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៣ | | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៤ | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | | | | | |
| ៣-៥ | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៦ | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | |
| ៣-៧ | | | | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | | |
| ៣-៨ | | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | |
| ៣-៩ | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | |
| ៣-១០ | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | |
| ៣-១១ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៤-១ | | | | | | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | |
| ៤-២ | | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | |
| ៤-៣ | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | |



๔-๕
๕-๑
๕-๒
๖-๑
๖-๒
๖-๓
๗-๑
๗-๒
๗-๓
๘-๑
๘-๒
๘-๓
๘-๔
๘-๕
๘-๖
๘-๗
๘-๘
๘-๙
๘-๑๐
๘-๑๑
๘-๑๒
๘-๑๓
๘-๑๔

| | |
|---|---|
| ៩-២ | |
| ៩-៣ | |
| ១០-១ | |
| ១០-២ | |
| ១០-៣ | |
| ១០-៤ | |
| ១០-៥ | |
| ១០-៦ | |
| ១០-៧ | |
| ១០-៨ | |
| ១០-៩ | |
| ១០-១០ | |

ថ្ងៃទី ១៧... ខែ ...សីហា... ឆ្នាំ ២០០៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

អ៊ុយ ណារ៉ុន

**តាមរយៈ មេឃុំព្រៃចាស់**

ហត្ថលេខា

ឈុន ណាង

លេខៈ ........................ ជផ

បានឃើញ និងឯកភាព

ថ្ងៃទី ......... ខែ ........... ឆ្នាំ ..............

**ប្រធានរដ្ឋបាលជលផល**